**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-May-2012, 14:32
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់លោក អៀង សារី សុំអនុញ្ញាតពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតផ្តល់ការធានាទាក់ទងទៅនឹងការមិនចោទប្រកាន់សាក្សី**

---

**<u>ដាក់ដោយ៖</u>**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**<u>ចម្លងជូន៖</u>**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ចៅក្រមបម្រុង ធូ មណី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន (“ក្រុមមេធាវីការពារក្តី”) អនុលោមទៅតាមវិធាន ៣៩(៤)(ក)[1] សូមស្នើជាបន្ទាន់សុំការអនុញ្ញាតពេលវេលាបន្ថែម រហូតដល់ថ្ងៃទី ១៥ មិថុនា ២០១២ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតផ្តល់ការធានាទាក់ទងទៅនឹងការមិនចោទប្រកាន់សាក្សី[2]។ សំណើសុំនេះជាការចាំបាច់ព្រោះថា: ក. សំណើសុំរបស់សហព្រះរាជអាជ្ញា លើកឡើងនូវបញ្ហាផ្លូវច្បាប់ដ៏ស្មុគស្មាញ ដែលតម្រូវអោយមានការពិចារណា និងការឆ្លើយតបអោយបានល្អិតល្អន់។ ខ. សំណើរបស់សហព្រះរាជអាជ្ញា ត្រូវបានដាក់នៅពេលដែលគូភាគីកំពុងស្ថិតក្នុងដំណើរការសាកសួរសាក្សីជាច្រើន។ គ. តម្រូវការអោយមានការដាក់ឯកសារជាពីរភាសាដែលកាត់បន្ថយនូវរយៈពេលដែលអាចមានសម្រាប់ការធ្វើពង្រាងការឆ្លើយតប និង ឃ. នាពេលខាងមុខនឹងមានថ្ងៃសម្រាកមួយចំនួន សម្រាប់បុគ្គលិកជាតិនៅថ្ងៃទី ១ មិថុនា[3] និងថ្ងៃទី ៤ មិថុនា[4] ដែលពេលនោះអ្នកបកប្រែនឹងមិនមកធ្វើការឡើយ។ យើងខ្ញុំសូមស្នើដោយក្តីគោរពថា រយៈពេលកំណត់ធម្មតា ១០ថ្ងៃ សម្រាប់ការឆ្លើយតបទៅលើញត្តិនានា[5] គឺមិនគ្រប់គ្រាន់នៅក្នុងករណីនេះឡើយ។ ដោយទទួលស្គាល់នូវសារៈសំខាន់នៃបញ្ហាដែលបានលើកឡើងនៅក្នុងសំណើសុំរបស់សហព្រះរាជអាជ្ញា និងតម្រូវការសម្រាប់ការពិចារណាអោយបានឆាប់រហ័សទៅលើសំណើសុំនោះ មេធាវីការពារក្តីសូមស្នើសុំនូវការបន្ថែមពេលវេលាបន្តិចបន្តួចចំនួន បួនថ្ងៃបន្ថែមពីលើពេលវេលាកំណត់ធម្មតាសម្រាប់ការដាក់ឯកសារ។

**អាស្រ័យហេតុនេះ** ដោយយោងលើហេតុផលទាំងអស់ខាងលើ មេធាវីការពារក្តី សូមស្នើសុំដោយក្តីគោរពដល់អង្គជំនុំជម្រះសាលាដំបូង មេត្តា**អនុញ្ញាត**បន្ថែមពេលវេលា ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតផ្តល់ការធានាទាក់ទងទៅនឹងការមិនចោទប្រកាន់សាក្សី រហូតដល់ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១២។

---

[1] វិធាន ៣៩(៤)(ក) នៃវិធានផ្ទៃក្នុងរបស់ អវតក អនុញ្ញាតអោយ អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតបន្ថែមពេលវេលាកំណត់។

[2] សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតផ្តល់ការធានាទាក់ទងទៅនឹងការមិនចោទប្រកាន់សាក្សី ចុះថ្ងៃទី ៣០ ឧសភា ២០១២ ឯកសារលេខ E200។

[3] *សូមមើល* សារាចរ ស្តីពី ថ្ងៃឈប់សំរាកសម្រាប់ឆ្នាំ ២០១២ ចុះថ្ងៃទី ១ ធ្នូ ២០១១។

[4] *សូមមើល* សារអេឡិចត្រូនិច ដែលផ្ញើរតាងនាមអោយការិយាល័យរដ្ឋបាល ស្តីពី “ការប្រកាសសម្រាប់បុគ្គលិកជាតិ របស់ អវតក ទាក់ទងទៅនឹងការបោះឆ្នោតឃុំ-សង្កាត់” ចុះថ្ងៃទី ២៩ ឧសភា ២០១២។

[5] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក វិ.៨ មាត្រា ៨.៣។

សូមលោកលោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

________________ ____________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានា**ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២**